.ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អគ្គនាយកដ្ឋានអប់រំ
នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

# របាយការណ៍លទ្ធផល
# ស្តីពី
# ការរៀបចំទិវាជាតិអំណានលើកទី ៦ ១១ មីនា ២០២១




ទីស្តីការ ក្រសួងអប់រំ យុវជន និងកីឡា
មីនា ២០២១

# មាតិកា

**ខ្លឹមសារ** **ទំព័រ**


**សេចក្តីផ្តើម** ..........៣

**I. គោលបំណង**..........៤

**II. យុទ្ធវិធី**..........៤

**III. លទ្ធផលសកម្មភាពនៃការប្រារព្ធទិវាជាតិអំណានលើកទី៦**..........៤

១. ដំណើរការរៀបចំទិវាជាតិអំណាន.......... ៤

២. ដំណើរការប្រឡងជ្រើសរើសបេក្ខជនជ័យលាភី.......... ៦

ក.ក្រុមប្រឡងប្រណាំងអានអត្ថបទ..........៦

ខ.ក្រុមប្រឡងប្រណាំងស្មូតកំណាព្យ..........៧

គ.ក្រុមប្រឡងប្រណាំងតែងនិពន្ធ..........៨

ឃ.ក្រុមប្រឡងប្រណាំងបកស្រាយស្នាដៃអក្សរសិល្ប៍..........៨

៣. សប្តាហ៍សៀវភៅ.......... ៩

៤. ការប្រារព្ធទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១..........១០

ក.របាយការណ៍វឌ្ឍនភាព ស្តីពី ការរៀបចំទិវាជាតិអំណាន..........១០

ខ.សុន្ទរកថាបើកទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១..........១១

គ.ការប្រកាសលទ្ធផលជ័យលាភីថ្នាក់ជាតិ..........១៣

ឃ.ការអានអត្ថបទ និងស្មូតកំណាព្យដោយជ័យលាភីលេខ១..........១៤

ង.បាឋកថា ស្រាវជ្រាវ ស្តីពី " អក្សរសិល្ប៍ និងភាសាខ្មែរសម័យកណ្តាល"................ ........................១៤

ច.ការបកស្រាយប្រធានបទ " តម្លៃនៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ " ..........១៥

ឆ.បទបង្ហាញ ស្តីពី " ស្ថានភាពបណ្ណាល័យនៅសាលាបឋមសិក្សាក្នុងប្រទេសកម្ពុជា "..........១៦

ជ.បទបង្ហាញ ស្តីពី " ការងារបណ្ណាល័យផ្សារភ្ជាប់នឹងសកម្មភាពអំណានដំបូង " ..........១៧

ឈ.ការចាក់បង្ហាញវីដេអូ ស្តីពី " សកម្មភាពអំណានក្នុងបណ្ណាល័យ "..........១៨

**ប្រសាសន៍ចូកសរុប និងបិទកម្មវិធី**..........១៩

**IV. សេចក្តីសន្និដ្ឋាន**..........២០

**V. ឧបសម្ព័ន្ធ**

**ឧបសម្ព័ន្ធទី១** ព័ត៌មាន និងគណៈកម្មការផ្សេងៗ សម្រាប់ទិវាជាតិអំណានលើកទី៦..........២១

រូបភាពទី ១ លិខិតលេខ០៤ អយក.សជណ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១..........២១

រូបភាពទី ២ លិខិតលេខ ២៦២ អយក.អកស ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១..........២៣

រូបភាពទី ៣ លិខិតលេខ ១៩ អយក.សសរ ចុះថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០២១ ..........២៤

រូបភាពទី ៤ លិខិតលេខ ៦៣៦ អយក.ឧទន ចុះថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០២១ ..........២៨

រូបភាពទី ៥ សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ..........៣១

**ឧបសម្ព័ន្ធទី២** បញ្ជីឈ្មោះបេក្ខជនចូលរួមប្រឡងប្រណាំង អាន ស្មូត តែងនិពន្ធ និងបកស្រាយ..........៣១

រូបភាពទី ៦ បញ្ជីឈ្មោះបេក្ខជនចូលរួមប្រឡងប្រណាំង " អានអត្ថបទ " ..........៣២

រូបភាពទី ៧ បញ្ជីឈ្មោះបេក្ខជនចូលរួមប្រឡងប្រណាំង " ស្មូតកំណាព្យ " ........................................៣៣
រូបភាពទី ៨ បញ្ជីឈ្មោះបេក្ខជនចូលរួមប្រឡងប្រណាំង " តែងនិពន្ធ " ...............................................៣៤
រូបភាពទី ៩ បញ្ជីឈ្មោះបេក្ខជនចូលរួមប្រឡងប្រណាំងបកស្រាយស្នាដៃអក្សរសិល្ប៍.............................៣៥
**ឧបសម្ព័ន្ធទី៣** បញ្ជីឈ្មោះបេក្ខជនជ័យលាភីលេខ១ លេខ២ លេខ៣ ទាំង៤ ផ្នែក.....................................៣៧
រូបភាពទី ១០ បញ្ជីឈ្មោះបេក្ខជនជ័យលាភីផ្នែក " អានអត្ថបទ " ........................................................៣៧
រូបភាពទី ១១ បញ្ជីឈ្មោះបេក្ខជនជ័យលាភីផ្នែក " ស្មូតកំណាព្យ " .....................................................៣៨
រូបភាពទី ១២ បញ្ជីឈ្មោះបេក្ខជនជ័យលាភីផ្នែក "តែងនិពន្ធ "...........................................................៣៩
រូបភាពទី ១៣ បញ្ជីឈ្មោះបេក្ខជនជម្រើស១០នាក់ដែលទទួលបានពិន្ទុលើសគេ " អក្សរសិល្ប៍ "..................៤០
រូបភាពទី ១៤ ចំណាត់ថ្នាក់ប្រឡងប្រណាំងបកស្រាយស្នាដៃអក្សរសិល្ប៍...................................................៤១
**ឧបសម្ព័ន្ធទី៤** អត្ថបទជ័យលាភីលេខ១ លេខ២ លេខ៣ ផ្នែកអាន ស្មូត និងតែងនិពន្ធ.............................៤៣
រូបភាពទី ១៥ ជ័យលាភីលេខ១ អត្ថបទអំណាន "រឿង អ្នកគ្រូរបស់គុណ " ..........................................៤៣
រូបភាពទី ១៦ ជ័យលាភីលេខ២ អត្ថបទអំណាន " ការសិក្សាក្នុងបរិបទជំងឺកូវីដ-១៩ " .............................៤៤
រូបភាពទី ១៧ ជ័យលាភីលេខ៣ អត្ថបទអំណាន " អំណានក្នុងបរិបទកូវីដ-១៩ " .................................៤៥
រូបភាពទី ១៨ ជ័យលាភីលេខ១ ស្មូតកំណាព្យ "អំណានក្នុងបរិបទកូវីដ-១៩ " .......................................៤៦
រូបភាពទី ១៩ ជ័យលាភីលេខ២ ស្មូតកំណាព្យ "អំណានដើម្បីអភិវឌ្ឍន៍ " .............................................៤៩
រូបភាពទី ២០ ជ័យលាភីលេខ៣ ស្មូតកំណាព្យ "គុណគ្រូ " ...............................................................៥០
រូបភាពទី ២១ ជ័យលាភីលេខ១ តែងនិពន្ធ "អំណានក្នុងបរិបទកូវីដ-១៩ " .........................................៥៣
រូបភាពទី ២២ ជ័យលាភីលេខ២ តែងនិពន្ធ "អំណានក្នុងសម័យកូវីដ-១៩ " .........................................៥៣
រូបភាពទី ២៣ ជ័យលាភីលេខ៣ តែងនិពន្ធ "អំណានក្នុងបរិបទកូវីដ-១៩ " .........................................៥៤
រូបភាពទី ២៤ បញ្ជីឈ្មោះ និងអ្នកតំណាងក្រុមហ៊ុន ចូលរួមតាំងពិព័រណ៍សៀវភៅតាមអនឡាញ..................៥៥




## សេចក្តីផ្តើម

យោងអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី " **ទិវាជាតិអំណាន** " ក្រសួងអយក. បានយកចិត្តទុកដាក់សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងធម្មការនិងសាសនា ដៃគូអភិវឌ្ឍ ស្ថាប័នឯកជន និងស្ថាប័ននានាតាំងពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ រៀបចំប្រារព្ធទិវាជាតិអំណានបាន៥លើករួចមកហើយ។

- លើកទី១ ឆ្នាំ២០១៦ នៅស.ភ.ព ក្រោមប្រធានបទ " **បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន** " មានអ្នកចូលរួម ១,៨៨៣ នាក់ ដោយមានការតាំងពិព័រណ៍សៀវភៅ១៨ស្តង់ មានការនិទានរឿង ការអានអត្ថបទ និងសូត្រកំណាព្យជានិមិត្តរូប។
- លើកទី២ ឆ្នាំ២០១៧ នៅ វ.ជ.អ ក្រោមប្រធានបទ " **អានដើម្បីភាពសុខដុមនៃជីវិត** " មានអ្នកចូលរួម ១,៨៥០ នាក់ ដោយមានកម្មវិធីប្រកួតប្រជែងអាន និងសូត្រកំណាព្យជាលើកដំបូង នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ សម្រាប់ទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ព្រមទាំងមានស្តង់តាំងពិព័រណ៍សៀវភៅ៣៣ស្តង់ ដែលចូលរួមដោយក្រុមហ៊ុន និងស្ថាប័ន២៨ និងមានអ្នកចូលរួមទស្សនា និងជាវសៀវភៅប្រមាណជាងបីម៉ឺននាក់។
- លើកទី៣ ឆ្នាំ២០១៨ នៅ វ.ប.ក ក្រោមប្រធានបទ " **អំណានជាកំណប់វិជ្ជាមហាសាល** " អ្នកចូលរួម ៣,៩៦៦នាក់ ដោយមានកម្មវិធីប្រកួតប្រជែងអាន និងសូត្រកំណាព្យ និងក្រសួងបានបន្ថែមកម្មវិធីប្រឡងប្រណាំងតែងនិពន្ធសម្រាប់សិស្សវិទ្យាល័យ ដើម្បីទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ព្រមទាំងមានស្តង់ថតរូប ស្តង់ពិព័រណ៍២៧ស្តង់ មានអ្នកទស្សនា និងជាវសៀវភៅ ប្រមាណជាងពីរម៉ឺននាក់ ពិសេសមានវាគ្មិនល្បីៗ មកធ្វើបាឋកថាទៀតផង។
- លើកទី៤ ឆ្នាំ២០១៩ នៅ វ.ប.ក ក្រោមប្រធានបទ " **ការអានបណ្តុះវប្បធម៌ ការសិក្សាពេញមួយជីវិត** " មានអ្នកចូលរួម ៤,០០០នាក់។ ការប្រព្រឹត្តទៅទិវាជាតិអំណានលើកទី៤នេះ មានលក្ខណៈសកម្មភាពដូចលើកទី៣ ឆ្នាំ២០១៨ដែរ តែមានស្តង់តាំងពិព័រណ៍សៀវភៅ៦៧ស្តង់ និងអ្នកចូលរួមទស្សនា និងជាវសៀវភៅកើនដល់ ៦៧.០០០ នាក់។
- លើកទី៥ ឆ្នាំ២០២០ នៅ វ.ប.ក ក្រោមប្រធានបទ " **ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍** " មានអ្នកចូលរួម ២.៥០០នាក់។ ការរៀបចំប្រារព្ធទិវាជាតិអំណាន លើកទី៥នេះ មាន លក្ខណៈសកម្មភាពដូចលើកទី៤ ដែរ។ ប៉ុន្តែក្នុងឱកាសនៃទិវានេះ ក្រសួងបានបន្ថែមកម្មវិធី មួយចំនួន ដូចជា ៖
  - សិក្ខាសាលា ស្តីពី " **អំណានដំបូង** " មានអ្នកជំនាញផ្នែកហ្វឹកហាត់អំណានមកធ្វើជាវាគ្មិន
  - សិក្ខាសាលា ស្តីពី " **ស្តង់ដារបណ្ណាល័យ** " មានអ្នកជំនាញការងារបណ្ណាល័យមកធ្វើបទបង្ហាញ
  - យុទ្ធនាការស្តីពី "តោះអានរាល់ថ្ងៃ" បានប្រព្រឹត្តទៅ១០ថ្ងៃ ដោយសហការឧបត្ថម្ភពីអង្គការមូលនិធិអាស៊ី
  - ស្តង់តាំងពិព័រណ៍សៀវភៅកើនដល់ ១០៤ ស្តង់ ចូលរួមដោយក្រុមហ៊ុន និងស្ថាប័នចំនួន ៨០

  ក្នុងសកម្មភាពស្តង់ពិព័រណ៍នេះ មានអ្នកចូលរួមទស្សនា និងជាវសៀវភៅ ចំនួន ២៥.០០០នាក់។

ជារួម ចាប់តាំងពីការរៀបចំទិវាជាតិអំណានលើកទី៣ ឆ្នាំ២០១៨មក ក្រសួងបានរៀបចំបន្ថែមកម្មវិធីជាបន្តបន្ទាប់ ក្នុងបំណងលើកកម្ពស់វប្បធម៌អាន ការស្រាវជ្រាវ និងការទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ជាពិសេសចំនួននៃស្តង់តាំងពិព័រណ៍ និងការចូលរួមពីមហាជនក្នុងការទស្សនា និងជាវសៀវភៅ ក៏មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ដោយឡែកឆ្នាំ២០២១នេះ ទោះបីស្ថិតក្នុងបរិបទនៃជំងឺកូវីដ-១៩ ក្រសួងអយក. នៅតែរៀបចំទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១ ក្រោមប្រធានបទ " **អំណានក្នុងបរិបទកូវីដ-១៩** " តាមអនឡាញ និងបានផ្សាយផ្ទាល់តាមគេហទំព័រ Facebook ផ្លូវការរបស់ក្រសួង។ ដើម្បីញ៉ាំងទិវានេះ ឱ្យប្រព្រឹត្តទៅមានភាពអធិកអធមថែមទៀត ក្រសួងបានរៀបចំឱ្យមាន៖

១).កម្មវិធីប្រឡងប្រណាំង អានអត្ថបទ សូត្រកំណាព្យ និងតែងនិពន្ធ ជ្រើសរើសជ័យលាភីលេខ១ លេខ២ និងលេខ៣ សម្រាប់ទទួល" **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន** " ។

២).ការជ្រើសរើសបេក្ខជន បេក្ខនារី ជ័យលាភី៣រូប ដែលមានសមត្ថភាពខ្ពស់ក្នុងការបកស្រាយប្រធានបទ ស្តីពី " តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ " ។

៣).កម្មវិធី " **សប្តាហ៍សៀវភៅ** " រយៈពេល៦ថ្ងៃ ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២១ តាមអនឡាញ

## I. គោលបំណង

ការប្រារព្ធទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១ តាមអនឡាញ ក្រោមប្រធានបទ " **អំណានក្នុងបរិបទកូវីដ-១៩** " មានគោលបំណង ៖

- បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន ស្នូតកំណាព្យ និងការតាក់តែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ ដល់សិស្ស និស្សិត មន្ត្រីរាជការ ប្រជាជនគ្រប់រូបក្នុងប្រទេសកម្ពុជា ព្រមទាំងលើកកម្ពស់ និងរក្សាគុណតម្លៃកេរដំណែលរបស់មនុស្សជាតិ
- សម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាព សំដៅធានាគុណភាពអប់រំ ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

### ពាក្យស្លោកសម្រាប់ទិវាជាតិអំណាន លើកទី៦

១.ការអានជាគន្លឹះនៃការអប់រំសម័យឌីជីថល
២.ការអានឆ្លាតវៃជួយអភិវឌ្ឍការអប់រំឌីជីថល
៣.អំណានលើកកម្ពស់ការធ្វើស្វ័យសិក្សាក្នុងបរិបទកូវីដ
៤.ការអានតាមប្រព័ន្ធបច្ចេកវិទ្យា លើកកម្ពស់ការសិក្សាក្នុងសម័យឌីជីថល
៥.អំណានដំបូង ជាមូលដ្ឋានគ្រឹះនៃគុណភាពអប់រំ
៦.អំណានក្នុងបណ្ណាល័យជួយបណ្តុះវប្បធម៌នៃការអាន
៧.អំណានជួយលើកកម្ពស់ការតែងនិពន្ធ
៨.ការអានជួយឱ្យយើងរស់នៅតាមគន្លងថ្មីក្នុងវិស័យអប់រំ
៩. អំណានតាមបច្ចេកវិទ្យា បណ្តុះសម្បទាការរស់នៅតាមគន្លងថ្មី
១០.ការអានជួយផ្សារភ្ជាប់ជំនាន់មនុស្ស

## II. យុទ្ធវិធី

ដើម្បីឱ្យការប្រារព្ធទិវាជាតិអំណានលើកទី៦ ឆ្នាំ២០២១ ក្នុងដំណាក់កាលជំងឺកូវីដ-១៩ ប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលល្អ ក្រសួងអយក. មានយន្តការសំខាន់ៗ ជាពដំណាក់កាលគឺ ៖

ដំណាក់កាលទី១ ការប្រជុំពិភាក្សារកយុទ្ធវិធីក្នុងការអនុវត្ត និងការរៀបចំលិខិតបទដ្ឋានគតិយុត្តិ

ដំណាក់កាលទី២ - ការប្រឡងប្រណាំងអានអត្ថបទ ស្នូតកំណាព្យ និងតែងនិពន្ធ ជ្រើសរើស បេក្ខជនជ័យលាភីលេខ១,២,៣
- ការជ្រើសរើសបេក្ខជន ជ័យលាភី៣រូប ដែលមានសមត្ថភាពខ្ពស់ក្នុងការបកស្រាយប្រធានបទអក្សរសិល្ប៍
- កម្មវិធី " សប្តាហ៍សៀវភៅ " រយៈពេល៦ថ្ងៃ ចាប់ពីថ្ងៃទី៩-១៤ ខែមីនា ឆ្នាំ ២០២១ តាមអនឡាញ

ដំណាក់កាលទី៣ ការប្រារព្ធទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១ តាមអនឡាញ។

## III. លទ្ធផលសកម្មភាពនៃការរៀបចំទិវាជាតិអំណានលើកទី៦

### ១.ដំណើរការរៀបចំទិវាជាតិអំណាន

ក្នុងដំណាក់កាលនេះ ក្រសួងបានរៀបចំ និងបំពេញកិច្ចការសំខាន់ៗជាច្រើន ដើម្បីត្រៀមរៀបចំឱ្យដំណើរការប្រារព្ធទិវាជាតិអំណានលើកទី៦ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ។

## ក.កិច្ចប្រជុំពិភាក្សា



- កិច្ចប្រជុំថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ នៅសាលប្រជុំ "ខ" នៃទីស្តីការក្រសួងអយក. ស្តីពី ការត្រៀមរៀបចំទិវាជាតិអំណានលើកទី៦ ដឹកនាំដោយ **លោកជំទាវ ទន់ សាអ៊ីម** អនុរដ្ឋលេខាធិការក្រសួងអយក.។

- កិច្ចប្រជុំថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ នៅសាលប្រជុំ "ក" នៃទីស្តីការក្រសួងអយក. ស្តីពី ការរៀបចំព្រឹត្តិបត្រទិវាជាតិអំណាន ដឹកនាំដោយ **ឯកឧត្តម បណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអយក.។



- កិច្ចប្រជុំថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ នៅសាលប្រជុំ "ក" នៃទីស្តីការក្រសួងអយក. ស្តីពី ការរៀបចំផែនការសកម្មភាពទិវាជាតិអំណានលើកទី៦ ដឹកនាំដោយ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្រ្តីក្រសួងអយក.។

- កិច្ចប្រជុំថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ នៅសាលប្រជុំ"ក" ទីស្តីការក្រសួងអយក. ស្តីពី ការត្រួតពិនិត្យផែនការរៀបចំទិវាជាតិអំណាន ដឹកនាំដោយ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

- កិច្ចប្រជុំតាមអនឡាញថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១ ជាមួយនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ស្តីពី ការប្រារព្ធទិវាជាតិអំណានលើកទី៦ តាមអនឡាញ ដឹកនាំកិច្ចប្រជុំដោយ **លោកជំទាវ គឹម សេដ្ឋានី** រដ្ឋលេខាធិការក្រសួងអយក.។

## ខ.ការរៀបចំលិខិតបទដ្ឋានគតិយុត្តិ

- លិខិតលេខ០៤ អយក.សជណ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ស្តីពី ការផ្សព្វផ្សាយដល់សាធារណជន លោកគ្រូ អ្នកគ្រូ គរុសិស្ស និងគរុនិស្សិត ចូលរួមប្រឡងប្រណាំងជ្រើសរើស បេក្ខជន បេក្ខនារី ជ័យលាភី៣រូប ដែលមានសមត្ថភាពខ្ពស់ក្នុងការបកស្រាយប្រធានបទ ស្តីពី " តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ " (ឧ.រូបភាពទី១)។

- លិខិតលេខ ២៦២ អយក.អកស ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ស្តីពី ការជម្រាបជូនមន្ទីរអយក.រាជធានី ខេត្ត ក្នុងការអនុវត្តសេចក្តីណែនាំលេខ ៤៧ អយក.សណន ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ (ឧ.រូបភាពទី២)។

- លិខិតលេខ ១៩ អយក.សសរ ចុះថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពី ការបង្កើតគណៈគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណាន (ឧ.រូបភាពទី៣)។

- លិខិតលេខ ៦៣៦ អយក.ឧទន ចុះថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពី ការចាត់តាំងថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំនៃក្រសួងអយក. ជាគណៈកម្មការវាយតម្លៃដាក់ពិន្ទុ និងរៀបចំការប្រឡងប្រណាំង ការអាន សូត្រកំណាព្យ តែងនិពន្ធ និងការបកស្រាយប្រធានបទ ស្តីពី "តម្លៃអក្សរសិល្ប៍រឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ" អបអរសាទរទិវាជាតិអំណានលើកទី៦ (ឧ.រូបភាពទី៤)។

- រៀបចំសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ស្តីពី ការប្រារព្ធទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១ តាមអនឡាញ(ឧ.រូបភាពទី៥)។

គ.ការត្រៀមរៀបចំសកម្មភាព



១.អនុគណៈកម្មការគ្រប់គ្រងសុន្ទរកថា ឯកសារ ព័ត៌មាន និងរបាយការណ៍ បានថតវីដេអូសម្រាប់ផ្សាយបន្តផ្ទាល់ក្នុងថ្ងៃប្រារព្ធទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១។




២. សហការជាមួយក្រុមការងារយុវជនស្ម័គ្រចិត្ត រៀបចំទិវាសប្ដាហ៍សៀវភៅ ចាប់ពីថ្ងៃទី ៩ ដល់ថ្ងៃទី១៤ ខែ មីនា ឆ្នាំ២០២១ ដើម្បីអបអរសាទរ ទិវាជាតិអំណានលើកទី៦ នេះ។

## ២.ដំណើរការប្រឡងជ្រើសរើសបេក្ខជនជ័យលាភី

កម្មវិធីប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីលេខ១ លេខ២ លេខ៣ ផ្នែកអានអត្ថបទ សូត្រកំណាព្យ និងតែងនិពន្ធ សម្រាប់ " **ពានរង្វាន់ សម្ដេចតេជោ ហ៊ុន សែន** " និងបេក្ខជន បេក្ខនារី ជ័យលាភី៣រូប ដែលមានសមត្ថភាពខ្ពស់ក្នុងការបកស្រាយប្រធានបទ ស្ដីពី " តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ " បានប្រព្រឹត្តទៅក្រោមការត្រួតពិនិត្យ និងវាយតម្លៃរបស់គណៈកម្មការវាយតម្លៃដាក់ពិន្ទុតាមផ្នែកនីមួយៗ តាមទីកន្លែង ពេលវេលា សកម្មភាព និងមានលទ្ធផល ដូចខាងក្រោម៖

**ក-ក្រុមប្រឡងប្រណាំងអានអត្ថបទ**

បានប្រព្រឹត្តទៅនាថ្ងៃទី៨-៩ ខែមីនា ឆ្នាំ២០២១ នៅសាលប្រជុំនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។

**ក.១** គណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំងអាន



១. លោក **ឃឹម សារិន** អនុប្រ. នា.អកស ប្រធាន
២. លោក **យ៉ង់ គំស៊ាន** ប្រ. ការិ.នា.អកស អនុប្រ.
៣. លោកស្រី **ផាន់ សុជាតា** មន្ត្រីនា.អកស សមាជិក
៤. លោក **ពា ឆ្វូយ** មន្ត្រី នា.អកស លេខាធិការ

**ក.២** បេក្ខជនចូលរួមប្រឡងប្រណាំង

បេក្ខជនមកពី ២៥ រាជធានី ខេត្ត សរុប ២៥ នាក់ ក្នុងនោះស្រី ២៣ នាក់ ជាសិស្សកំពុងសិក្សានៅថ្នាក់ទី៦ នៃបឋមសិក្សាចំណេះទូទៅ (ឧ. រូបភាពទី៦ )។

**ក.៣** លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកអានអត្ថបទ

. អានអត្ថបទបានលឿន គោរពឃ្លា ល្បះបានត្រឹមត្រូវ ២ ពិន្ទុ . មិនខុសពាក្យ មិនរំលងពាក្យ ៤ ពិន្ទុ
. សំឡេង សំនៀងច្បាស់ៗ ត្រឹមត្រូវតាមសូររបស់ពាក្យ ៣ ពិន្ទុ . ឥរិយាបថសមរម្យ ១ ពិន្ទុ

**ក.៤ សកម្មភាពវាយតម្លៃដាក់ពិន្ទុ**



ក្នុងការវាយតម្លៃដាក់ពិន្ទុ សមាជិកគណៈកម្មការមិនបានជួបជុំទាំងអស់គ្នាទេ គឺធ្វើតាមអនឡាញ ដោយលើកយកវីដេអូរបស់បេក្ខជនជ័យលាភីលេខ១ ដែលបានបញ្ជូនមកពីរាជធានី ខេត្តទាំង ២៥ មកមើល ស្ដាប់ ពិនិត្យ និងវាយតម្លៃដាក់ពិន្ទុ ដើម្បីជ្រើសរើសយកបេក្ខជនជ័យលាភីលេខ១ លេខ២ និងលេខ៣ ក្នុងចំណោមបេក្ខជន២៥នាក់នោះ ។

លទ្ធផល បេក្ខជនទទួលបានជ័យលាភីអានអត្ថបទ មានះ

**លេខ១** កុមារី **យុន ជីនីតា** រៀនថ្នាក់ទី៦ ប.អនុវត្ត ខេត្តព្រះវិហារ អានអត្ថបទះ " *រឿង អ្នកគ្រូរបស់គុណ* " (ឧ. រូបភាពទី១៥ )

**លេខ២** កុមារា **ឡេង រក្សា** ថ្នាក់ទី៦ ប.ព្រៃទទឹង ខេត្តកំ.ចាម អានអត្ថបទះ "*ការសិក្សាក្នុងបរិបទជំងឺកូវីដ-១៩*" (ឧ.រូបភាពទី១៦)

**លេខ៣** កុមារី **ខឿន ស្រីនូ** ថ្នាក់ទី៥ ប.សម្ដេចក្រុមព្រះ ខេត្តតេនគីរី អានអត្ថបទះ " *អំណានក្នុងបរិបទកូវីដ-១៩* " (ឧ. រូបភាពទី១៧)

**ខ-ក្រុមប្រឡងប្រណាំងស្មូតកំណាព្យ**

បានប្រព្រឹត្តទៅនាថ្ងៃទី៨-៩ ខែមីនា ឆ្នាំ២០២១ នៅសាលប្រជុំ នៃអគាររដ្ឋបាលថៅពញាហុក។

**ខ.១** គណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំងស្មូតកំណាព្យ

| | | | |
|---|---|---|---|
| ១. លោកជំទាវ បណ្ឌិត | **សឿ សុជាតា** | អនុរដ្ឋ.ក្រសួងអយក. | ប្រធាន |
| ២. លោកស្រី | **ម៉ៅ តាន់ណារ៉ាទី** | អនុប្រ.កា.វិ.នា.អកស. | អនុប្រធាន |
| ៣. លោក | **ខិន សុតារា** | អនុប្រ.កា.វិ.នា.អកស. | សមាជិក |
| ៤. លោក | **យូ លក្ខិណា** | អនុប្រ.កា.វិ.នា.អកស. | សមាជិក |
| ៥. លោក | **ដាំ បេខ** | មន្ត្រី នា.អកស. | លេខាធិការ |

**ខ.២** បេក្ខជនចូលរួមប្រឡងប្រណាំង

បេក្ខជនមកពី ២៥ រាជធានី ខេត្ត សរុបមាន ២៥ នាក់ក្នុងនោះស្រី ២១ នាក់ ជាសិស្សកំពុងសិក្សានៅថ្នាក់ទី៧,៨,៩ នៃអនុវិទ្យាល័យចំណោះទូទៅ (ឧ. រូបភាពទី៧ )។

**ខ.៣** លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកស្មូតកំណាព្យ

. សំឡេងមិនដាច់ មិនភ្លាត់ ឬភ្លាវនាំឱ្យខុសចង្វាក់ ២ ពិន្ទុ . ស្មូតគោរពតាមលំនាំបទនៃកំណាព្យ ៤ ពិន្ទុ

. ទឹកមុខ កាយវិការទៅតាមបរិយាកាសនៃបទនីមួយៗ ១ ពិន្ទុ . ទឹកដមពីរោះក្រអៅក្រអួន ៣ ពិន្ទុ

**ខ.៤ សកម្មភាពវាយតម្លៃដាក់ពិន្ទុ**



ក្នុងការវាយតម្លៃដាក់ពិន្ទុ គណៈកម្មការបានជួបប្រជុំគ្នាតាមអនឡាញ ដោយយកវីដេអូរបស់បេក្ខជនជ័យលាភីលេខ១ ដែលបានបញ្ជូនមកពីរាជធានី ខេត្តទាំង២៥ មកមើល ស្ដាប់ ពិនិត្យ និងវាយតម្លៃដាក់ពិន្ទុ ដើម្បីជ្រើសរើសយកបេក្ខជនជ័យលាភីលេខ១ លេខ២ និងលេខ៣ ក្នុងចំណោម២៥នាក់នោះ ។

លទ្ធផល បេក្ខជនទទួលបានជ័យលាភីស្នូតកំណាព្យ មានៈ

**លេខ១** កុមារី **រឹង ស្រីពេជ្រ** រៀនថ្នាក់ទី៧ វិទ្យាល័យ ស្តៅសន្តិភាព ខេត្តបាត់ដំបង
កំណាព្យបទពាក្យ៧ សូត្របែបមេទ្រីបា មានចំណងជើង "*អំណានក្នុងបរិបទកូវីដ-១៩*"(ឧ.រូបទី១៨)

**លេខ២** កុមារី **វ៉ាត ចន្ទសោភា** រៀនថ្នាក់ទី៩ វិទ្យាល័យ ស្រអែម ខេត្តព្រះវិហារ
កំណាព្យបទពាក្យ៧ សូត្របែបមេទ្រីបា មានចំណងជើង "*អំណានដើម្បីអភិវឌ្ឍន៍*"(ឧ.រូបទី១៩)

**លេខ៣** កុមារា **ខុម បញ្ញា** រៀនថ្នាក់ទី៩ អនុវិទ្យាល័យអំពិលទោល ខេត្តព្រៃវែង
កំណាព្យបទពាក្យ៧ សូត្របែប ខមាទោស មានចំណងជើង " *គុណគ្រូ* " (ឧ.រូបភាពទី២០)

## គ-ក្រុមប្រឡងប្រណាំងតែងនិពន្ធ

បានប្រព្រឹត្តទៅនាថ្ងៃទី៨-៩ ខែមីនា ឆ្នាំ២០២១ នៅសាលប្រជុំ "ខ" ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ។

**គ.១** គណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំងតែងនិពន្ធ



១. លោកជំទាវ **ធន់ សាអ៊ីម** អនុរដ្ឋ. ក្រ.អយក. ប្រធាន
២. លោក **យិន ធី** អនុប្រ. នា.អកស អនុប្រ
៣. លោក **ប៉ៃ្រ សំបូរ** អនុប្រ. ការិ.នា.អកស សមាជិក
៤. លោក **ហ៊ីន ឡាច** មន្ត្រី នា.អកស លេខាធិការ

**គ.២** បេក្ខជនចូលរួមប្រឡងប្រណាំង

បេក្ខជនមកពី ២៥ រាជធានី ខេត្ត សរុបមាន ២៥ នាក់ក្នុងនោះស្រី ១៧ នាក់ ជាសិស្សកំពុងសិក្សានៅថ្នាក់ទី១០,១១,១២ នៃវិទ្យាល័យចំណោះទូទៅ (ឧ. រូបភាពទី៨)។

**គ.៣** លក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកតែងនិពន្ធ

. អត្ថរូប រចនាបទ (រង្វាស់កាព្យ ចំណាប់ចួនភាសាកាព្យ) ៣ ពិន្ទុ . អត្ថន័យ (ត្រឹមត្រូវតាមប្រធានបទ) ៣ ពិន្ទុ
. អត្ថរស ( តម្លៃអប់រំ តម្លៃគុណធម៌ និងតម្លៃសីលធម៌ ) ៣ ពិន្ទុ . អក្ខរាវិរុទ្ធ ១ ពិន្ទុ

**គ.៤** សកម្មភាពវាយតម្លៃដាក់ពិន្ទុ

ក្នុងការវាយតម្លៃដាក់ពិន្ទុ គណៈកម្មការបានយកអត្ថបទរបស់បេក្ខជនជ័យលាភីលេខ១ ដែលបានបញ្ជូនមកពីរាជធានីខេត្តទាំង២៥ មកមើល វិភាគ និងវាយតម្លៃដាក់ពិន្ទុ ដើម្បីជ្រើសរើសយកបេក្ខជនជ័យលាភីលេខ១ លេខ២ និងលេខ៣ ក្នុងចំណោម២៥នាក់នោះ ។ បេក្ខជន ទទួលបានជ័យលាភីក្នុងការតែងនិពន្ធ មានៈ

**លេខ១** កុមារី **គុង មិនា** រៀនថ្នាក់ទី១០ វិទ្យាល័យព្រះ បាទសុរាម្រឹត ខេត្តកំពង់ឆ្នាំង
តែងនិពន្ធអត្ថបទកំណាព្យ មានចំណងជើងថា " *ការអានក្នុងបរិបទកូវីដ-១៩* " (ឧ.រូបភាពទី២១)

**លេខ២** កុមារី **អាន រក្សា** រៀនថ្នាក់ទី១១ វិទ្យាល័យ ក្រែក ខេត្តត្បូងឃ្មុំ
តែងនិពន្ធអត្ថបទកំណាព្យ មានចំណងជើងថា "*អំណានក្នុងសម័យកូវីដ-១៩*"(ឧ.រូបភាពទី២២)

**លេខ៣** កុមារី **អេង ស្រីយ៉ា** រៀនថ្នាក់ទី១១ វិទ្យាល័យ ជ្រោះប៊ូស្រា ខេត្តមណ្ឌលគិរី
តែងនិពន្ធអត្ថបទកំណាព្យ មានចំណងជើងថា "*អំណានក្នុងបរិបទកូវីដ-១៩*" (ឧ.រូបភាពទី២៣)

## ឃ-ក្រុមប្រឡងប្រណាំងបកស្រាយស្នាដៃអក្សរសិល្ប៍

បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១-៨ ខែមីនា ឆ្នាំ២០២១ នៅសាលប្រជុំ " ក និង ខ" នៃទីស្តីការក្រសួងអយក.។

ឃ.១ គណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំងបកស្រាយស្នាដៃអក្សរសិល្ប៍



១. ឯ.ឧ.បណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

រដ្ឋ.ក្រសួង អយក. ប្រធាន

២. លោកជំទាវ **ឆន់ សារ៉ុម**

អនុរដ្ឋ. ក្រសួងអយក. អនុប្រធាន

៣. លោកជំទាវបណ្ឌិត **ឃួន វិច្ឆិកា**

អគ្គនា.រង អគ.អរ សមាជិក

| | | | |
|---|---|---|---|
| ៤.លោក **យិន** | **ធី** | អនុប្រ. នា.អកស | សមាជិក |
| ៥.លោក **ព្រៃ** | **សំបូរ** | អនុប្រ. ការិ.នា.អកស | សមាជិក |
| ៦.លោក **សុខ** | **បញ្ញាវឌ្ឍន៍** | មន្ត្រី នា.អកស | លេខាធិការ |

ឃ.២ បេក្ខជនចូលរួមប្រឡងប្រណាំង

មកពី ២៥រាជធានី-ខេត្ត មាន២៦នាក់/ស្រី ៦នាក់ ជាគ្រូបង្រៀន សិស្ស និស្សិត និងបុគ្គលិក មន្ទីរអយក.(ឧ.រូបភាពទី៩)

ឃ.៣ សកម្មភាពវាយតម្លៃដាក់ពិន្ទុ

គណៈកម្មការវាយតម្លៃដាក់ពិន្ទុ បានធ្វើការវាយតម្លៃដោយចែកចេញជា ២ លើក មានដូចខាងក្រោម៖
លើកទី១ ថ្ងៃទី១-៣ ខែមីនា ឆ្នាំ២០២១ ធ្វើការវាយតម្លៃជ្រើសរើសបេក្ខជនមានពិន្ទុលើសគេ១០នាក់ (ឧ.រូបភាពទី១៣)
លើកទី២ ថ្ងៃទី៦-៨ ខែមីនា ឆ្នាំ២០២១ វាយតម្លៃជ្រើសរើសយកបេក្ខជនជ័យលាភី ៣នាក់ ក្នុង១០ នាក់។ ប៉ុន្តែលទ្ធផល គឺបេក្ខជន៤នាក់មានពិន្ទុលើសគេ ក្នុងនោះ២នាក់មានពិន្ទុស្មើគ្នា ដោយមានការឯកភាពពី **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** គណៈកម្មការសម្រេចជ្រើសបានបេក្ខជនជ័យលាភីលេខ១ លេខ២ និងលេខ៣ស្ទួន មានដូចខាងក្រោម ៖

| | | | | | |
|---|---|---|---|---|---|
| លេខ១ លោក | ជក់ | សុភា | គ្រូបង្រៀន | សាលាជំនាន់ថ្មី វិទ្យាល័យព្រែកលាប | រាជធានីភ្នំពេញ |
| លេខ២ លោក | រ៉ឹក | សាវន់ | គ្រូឧទ្ទេស | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៃវែង | ខេត្តព្រៃវែង |
| លេខ៣ លោក | ទឹម | សុខហួយ | គ្រូបង្រៀន | វិទ្យាល័យ អង្គសង្កែ | ខេត្តតាកែវ |
| លេខ៣ លោក | ឡុង | ធរង្ស | គ្រូបង្រៀន | វិទ្យាល័យ សម្តេចអគ្គ.ហ៊ុន សែន សំរោង | រាជធានីភ្នំពេញ |

## ៣.សប្តាហ៍សៀវភៅ




សប្តាហ៍សៀវភៅ ជាព្រឹត្តិការណ៍មួយដែលរៀបចំឡើងសហការរវាងក្រុមការងារយុវជនស្ម័គ្រចិត្តជាមួយក្រសួងអយក. រៀបចំពិព័រណ៍សៀវភៅតាមអនឡាញ ដើម្បីអបអរសាទរទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១។ ក្រុមយុវជនស្ម័គ្រចិត្ត បានរៀបចំចាប់ផ្តើមពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២១ មានលទ្ធផលដូចខាងក្រោម ៖

- ការផ្សព្វផ្សាយព័ត៌មាន បានទៅដល់អ្នកនៅលើបណ្តាញសង្គម ចំនួន ១,៨១០,៧១៣ គណនី
- អ្នកចូលរួមក្នុងសកម្មភាពលើទំព័រ និងវីដេអូ ៣៥៤,៦៩២ គណនី
- ការចូលរួមតាំងពិព័រណ៍ពីក្រុមហ៊ុនមាន ២៤ ក្រុមហ៊ុន (ឧ.រូបភាពទី ២៤)។

## ៤.ការប្រារព្ធទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១



ការប្រារព្ធទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១ បានប្រព្រឹត្តិទៅនាថ្ងៃព្រហស្បតិ៍ ១៣រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ក្រោមប្រធានបទ " **អំណានក្នុងបរិបទកូវីដ -១៩** " តាមអនឡាញ ពីទីស្តីការក្រសួងអយក. ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអយក. និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួង អង្គភាពក្រោមឱវាទទីស្តីការ មន្ទីរអយក. រាជធានី ខេត្ត តាមរយៈតំណZoom https://fb.me/e/Y7V0SImO មាន៥០០នាក់ និងផ្សាយបន្តផ្ទាល់តាម Facebook.com/moeys.gov.kh និង Youtube.com/MoEYSCambodia ផងដែរ។

ដំណើរការប្រព្រឹត្តទៅនៃទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១ បានប្រព្រឹត្តទៅតាមកម្មវិធី ដែលមានសកម្មភាព និងខ្លឹមសារដូចខាងក្រោម៖

### ក. របាយការណ៍វឌ្ឍនភាព ស្តីពី ការរៀបចំទិវាជាតិអំណាន




លោក **ស៊ុន ម៉ិណ្ណា** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា បានបង្ហាញពីវឌ្ឍនភាពនៃការរៀបចំទិវាជាតិអំណានជូនអង្គពិធីថា បន្ទាប់ពីរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១២០ អនក្រ .បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពី ទិវាជាតិអំណាន រួចមកក្រសួងអយក.បានសហការជាមួយក្រសួងពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍ រៀបចំទិវាជាតិអំណានបាន៥លើករួចមកហើយ មាន៖

- លើកទី១ ឆ្នាំ២០១៦ ក្រោមប្រធានបទ " **បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន** " មានអ្នកចូលរួម ១,៨៨៣ នាក់ នៅស.ភ.ព ដោយមានកម្មវិធីអាន និងសូត្រកំណាព្យជានិមិត្តរូប ។

- លើកទី២ ឆ្នាំ២០១៧ ក្រោមប្រធានបទ " **អានដើម្បីភាពសុខដុមនៃជីវិត** " មានអ្នកចូលរួម ១,៨៥០ នាក់ ដោយមានកម្មវិធីប្រកួតប្រជែងអាន និងសូត្រកំណាព្យជាលើកដំបូង នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ សម្រាប់ទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ព្រមទាំងមានស្តង់តាំងពិព័រណ៌ សៀវភៅ៣៣ស្តង់ ដែលចូលរួមដោយក្រុមហ៊ុននិងស្ថាប័ន២៨ និងមានអ្នកចូលរួមទស្សនា និងជាវសៀវភៅប្រមាណជាងបីម៉ឺននាក់។

- លើកទី៣ឆ្នាំ២០១៨ ក្រោមប្រធានបទ "**អំណានជាកំណប់វិជ្ជាមហាសាល**" មានអ្នកចូលរួម ៣,៩៦៦នាក់។ ឆ្នាំទី៣នេះ ក៏មានកម្មវិធីប្រកួតប្រជែងអាន និងសូត្រកំណាព្យដើម្បីទទួល " **ពានរង្វាន់ សម្តេចតេជោ ហ៊ុន សែន**" ព្រមទាំងការរៀបចំស្តង់ថតរូប ស្តង់ពិព័រណ៌សៀវភៅ២៧ស្តង់ និងមានវាគ្មិនល្បីៗ មកធ្វើបាឋកថាទៀតផង។

- លើកទី៤ ឆ្នាំ២០១៩ ក្រោមប្រធានបទ " **ការអានបណ្តុះវប្បធម៌ ការសិក្សាពេញមួយជីវិត** " មានអ្នកចូលរួម៤,០០០នាក់ ព្រមទាំងមានស្តង់តាំងពិព័រណ៌៦៧ស្តង់ និងអ្នកចូលរួមទស្សនា និងជាវសៀវភៅកើនដល់ ៦៧០០០នាក់។ ក្នុងឱកាសនៃទិវានោះ មានការចែកនូវឯកសារ ដែលជាស្នាដៃនិពន្ធរបស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ជូនដល់អ្នកចូលរួមក្នុងកម្មវិធីទិវាជាតិអំណានលើកទី៤ និងអ្នកទស្សនា និងជាវសៀវភៅ។

- លើកទី៥ ឆ្នាំ២០២០ ក្រោមប្រធានបទ " **ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍** " មានអ្នកចូលរួម ២៥០០នាក់។ ក្នុងទិវានេះ ក្រសួងបានបន្ថែមកម្មវិធីមួយចំនួនលើសពីឆ្នាំ២០១៩ ដូចជា សិក្ខាសាលា ស្តីពី " អំណានដំបូង ",

" ស្តង់ជាបណ្ណាល័យ " និងយុទ្ធនាការ ស្ដីពី " គោះអានរាល់ថ្ងៃ " ដែលបានប្រព្រឹត្តទៅរយៈពេល១០ ថ្ងៃ ជាពិសេសស្តង់តាំងពិព័រណ៍សៀវភៅកើនដល់១០៤ ស្តង់ ចូលរួមដោយក្រុមហ៊ុន និងស្ថាប័នចំនួន ៨០។

ដោយឡែកឆ្នាំ២០២១ ទោះបីស្ថិតក្នុងបរិបទនៃជំងឺកូវីដ-១៩ ក្រសួងអយក. នៅតែរៀបចំទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១ ក្រោមប្រធានបទ " អំណានក្នុងបរិបទកូវីដ-១៩ " តាមអនឡាញទាំងស្រុង។

## ខ.សុន្ទរកថាបើកទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១




ប្រសាសន៍ **ឯកឧត្តម បណ្ឌិតសភាចារ្យ** រដ្ឋមន្ត្រីក្រសួងអយក. ក្នុងឱកាសនៃពិធីបើកមានខ្លឹមសារដូចខាងក្រោម៖

. កិច្ចស្វាគមន៍ដ៏ស្មោះស្ម័គ្រចំពោះអ្នកពាក់ព័ន្ធ និងមហាជនក្នុងការចូលរួមទស្សនា និងតាមដានការប្រារព្ធទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១ ដែលកំពុងធ្វើឡើងតាមអនឡាញ។

. ដើម្បីចូលរួមអបអរសាទរ " ទិវាជាតិអំណាន ១១ មីនា " ផង និងបន្តអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ផង ក្រសួងអយក. នៅតែប្រារព្ធទិវាជាតិអំណានដូចរៀងរាល់ឆ្នាំ ក្នុងគោលបំណងរំឭកដល់វីរភាព **សម្ដេចព្រះសង្ឃរាជ ជួន ណាត** ដែលបានខិតខំតស៊ូ ពុះពារការពារមរតកវប្បធម៌អក្សរសាស្ត្រខ្មែរ និងក្នុងគោលបំណងបណ្ដុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ។

.ទិវាជាតិអំណានលើកទី៦ ប្រារព្ធឡើងក្រោមប្រធានបទ " **អំណានក្នុងបរិបទកូវីដ-១៩** " នៅពេលនេះ មានបំណងរំលេចឱ្យឃើញអំពីទស្សនាទានថ្មីនៃអំណាន រួមទាំងខ្លឹមសារសម្រាប់អំណាន, មធ្យោបាយអាន និងការផ្ដល់នូវបទអន្តរាគមចាំបាច់សម្រាប់ គាំទ្រដល់អំណានក្នុងបរិបទកូវីដ-១៩។

. អំណានអាចជួយដល់ «ការស្ដាប់» របស់អ្នកដោយមិនច្រឡំអត្ថន័យ , ជួយដល់ «ការនិយាយ» របស់អ្នកឲ្យបានល្អ និងជួយដល់ «ការសរសេរ» របស់អ្នកឲ្យត្រូវតាមវេយ្យាករណ៍ ស្របនឹងពាក្យស្លោក អានកាន់តែច្រើន ដឹងកាន់តែច្រើន, អានកាន់តែច្រើន ចេះកាន់តែច្រើន។

. សៀវភៅ ជាឃ្លាំងប្រាជ្ញានិងជាធនាគារនៃគំនិត ជាគ្រូអាចារ្យ ជាមិត្តល្អរបស់យើង និងជាអ្នកដឹកនាំ ឬជាចង្កៀងបំភ្លឺផ្លូវជីវិតឆ្ពោះទៅរកជីវិតក្សេមក្សាន្តរុងរឿង។

. មធ្យោបាយសម្រាប់អំណានមានច្រើន តាមការចូលចិត្ត រួមមាន អានតាមសៀវភៅ អានលើឧបករណ៍អេឡិចត្រូនិក អាននៅលើទូរសព្ទឆ្លាត និងអាននៅលើកុំព្យូទ័រ ដែលទាំងនេះសុទ្ធសឹងជាមធ្យោបាយសំខាន់ៗ នាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានផងដែរ។ នាពេលបច្ចុប្បន្ន សិស្សានុសិស្ស និស្សិត និងយុវជនកម្ពុជាដែលស្រឡាញ់អំណាន ក៏កំពុងតែប្រើប្រាស់មធ្យោបាយអានទាំងនេះផងដែរ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំអេឡិចត្រូនិក និងឯកសារគ្រប់គ្រាន់ដែលបានបង្ហោះឡើង សម្រាប់អំណាន។

. ក្នុងបរិបទកម្ពុជា កំពុងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡាបានជំរុញការអប់រំតាមបែបឌីជីថល និងការបង្រៀនពីចម្ងាយតាមបែបប្រពៃណី ដើម្បីលើកកម្ពស់អំណាន តាមរយៈការផ្ដល់សៀវភៅសិក្សាគោលដល់សិស្ស ការផលិតវីដេអូបង្រៀន ការបែងចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការបង្ហោះមេរៀន និងឯកសារផ្សេងៗនៅតាមបណ្ដាញផ្សព្វផ្សាយផ្លូវការ និងបណ្ដាញផ្សព្វផ្សាយរបស់ដៃគូពាក់ព័ន្ធ។

ទោះជាយ៉ាងណា អ្នកសិក្សាមិនអាចមានលទ្ធភាពទទួលបាន និងចាប់យកឱកាសនៃអំណានដូចៗគ្នាបានទេ ដោយសារកត្តាភូមិសាស្ត្រ បច្ចេកវិទ្យា ធនធាន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ។ ម៉្យាងវិញទៀត អំណាននៅក្នុងបរិបទកូវីដ-១៩ ក៏នៅតែត្រូវការបកស្រាយ និងជួយពន្យល់បន្ថែមពីគ្រូបង្រៀន និងមាតាបិតា អ្នកអាណាព្យាបាល ដែលទាមទារឱ្យក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធរអប់រំគ្រប់លំដាប់ថ្នាក់ និងគ្រឹះស្ថានសិក្សាត្រូវស្វែងរកអន្តរាគមន៍ជួយគាំទ្របន្ថែមទៀត។

ដើម្បីលើកកម្ពស់ អំណានក្នុងបរិបទកូវីដ-១៩ ឱ្យកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀត ដល់សិស្សានុសិស្ស និស្សិត និងយុវជន **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានផ្តល់នូវអនុសាសន៍សំខាន់ៗមួយចំនួន ដូចខាងក្រោម៖

១. អ្នកនិពន្ធ និងអ្នកចងក្រងសៀវភៅ ឬឯកសារអប់រំ សូមបន្ត និងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេស ធនធានអំណានជាភាសាខ្មែរ

២ . ក្រសួង ស្ថាប័នពាក់ព័ន្ធ សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យមន្ត្រីរាជការ និងបុគ្គលិកគ្រប់រូប ចូលរួមអាន និងសិក្សាស្រាវជ្រាវ តាមគ្រប់លទ្ធភាព ជាពិសេសការរៀបចំឱ្យមាន បណ្ណាល័យ ឬមជ្ឈមណ្ឌលរក្សាឯកសារ ឌីជីថល

៣ .ក្រសួងអប់រំ យុវជន និងកីឡាត្រូវបន្តពង្រីកកម្មវិធីអប់រំ ដែលជាមូលដ្ឋានគ្រឹះសម្រាប់សិស្សានុសិស្ស និងយុវជនអាចមានលទ្ធភាពបន្តការសិក្សាទៅកម្រិតសិក្សាបន្តទៀត ដូចជា កម្មវិធីអំណានដំបូងនៅបឋមសិក្សា កម្មវិធីកុមាររៀនកុមារចេះ អក្ខរកម្មនៅតាមរោងចក្រ សហគ្រាស ពន្ធនាគារ ។ល។ ព្រមទាំងបន្តខិតខំបង្កើតមាតិកាអប់រំសម្រាប់អំណានតាមបែបឌីជីថលបន្ថែមទៀត

៤ .គ្រឹះស្ថានសិក្សា មណ្ឌលសិក្សា ទីវត្តអារាមទាំងអស់ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុង ការបង្កើតបណ្ណាល័យ ឬជ្រុងអំណាន ដើម្បីឱ្យសិស្សានុសិស្ស និស្សិត សាមណសិស្ស សាមណនិស្សិត អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបនឹងតម្រូវការអ្នកអាន

៥ .ក្មួយៗជាសិស្ស និស្សិតតាមគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន និងយុវជនទាំងអស់ ត្រូវខិតខំ និង ចំណាយពេលអាន

៦ .បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញ និងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយក្នុងគ្រួសារ សម្រាប់ការទិញសម្ភារសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដទៃទៀត ដល់កូនៗជាទីស្រឡាញ់ ដែលចាត់ទុកជាការវិនិយោគ មួយដ៏សំខាន់សម្រាប់បង្កើនចំណេះដឹង និងដើម្បីអនាគតដ៏ត្រចះត្រចង់របស់ពួកគេ។

**ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានបង្ហាញពីកម្មវិធីសំខាន់ក្នុងការប្រារព្វទិវាជាតិអំណានលើកទី ៦ នេះមាន ការប្រកួតប្រជែងអានអត្ថបទ ស្មូតកំណាព្យ និងការតែងនិពន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងរៀបចំវេទិកាបកស្រាយស្នាដៃអក្សរសិល្ប៍ដែលមានប្រធានបទ " **តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ** "។ ក្រៅពីនេះ ក្រសួងបានរៀបចំឱ្យមានកម្មវិធីមួយចំនួនទៀត ដូចជា ការរៀបចំ " សប្តាហ៍សៀវភៅ " តាមអនឡាញ បទបង្ហាញស្តីពី " ស្ថានភាពបណ្ណាល័យនៅសាលាបឋមសិក្សានៅក្នុងប្រទេសកម្ពុជា " និងបទបង្ហាញស្តីពី "ការងារបណ្ណាល័យ ផ្សារភ្ជាប់នឹងសកម្មភាពអំណានដំបូង" ពិសេសបាឋកថាស្រាវជ្រាវ ស្តីពី " អក្សរសិល្ប៍ និងភាសាខ្មែរ សម័យកណ្តាល តាមរយៈសិលាចារឹកនគរវត្ត" ដោយ **ឯកឧត្តម**ផ្ទាល់ផងដែរ។

ចុងបញ្ចប់ **ឯកឧត្តម បណ្ឌិតសភាចារ្យ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ដើម្បីអភិវឌ្ឍជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យ ក្រោមម្លប់សន្តិភាព និងការអភិវឌ្ឍ ជាពិសេសក្នុងដំណាក់កាលនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នាពេលបច្ចុប្បន្ន និងបានថ្លែងអំណរគុណដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ វិស័យឯកជន គ្រឹះស្ថានសិក្សា និងអ្នកពាក់ព័ន្ធគ្រប់រូប ជាពិសេសគណៈកម្មការរៀបចំគ្រប់លំដាប់ថ្នាក់ ដែលបានចាត់ចែងនិងរៀបចំដំណើរការពិធីនេះបានល្អប្រសើរ។

## គ.ការប្រកាសលទ្ធផលជ័យលាភីថ្នាក់ជាតិ ផ្នែកអានអត្ថបទ ស្មូតកំណាព្យ តែងនិពន្ធ និងជ័យលាភី បកស្រាយប្រធានបទ " តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ "

### ជ័យលាភី ផ្នែកអានអត្ថបទ




ជ័យលាភីលេខ១ កុមារី **យុន ជីនីតា** សិស្សរៀន ប.អនុវត្ត ខេត្តព្រះវិហារ
ទទួលបានថវិកាលើកទឹកចិត្ត ៣.០០០.០០០៛
ជ័យលាភីលេខ២ កុមារា **ឡេង រក្សា** សិស្សរៀន ប.ព្រៃទទឹង ខេត្តកំពង់ចាម
ទទួលបានថវិកាលើកទឹកចិត្ត ២.០០០.០០០៛
ជ័យលាភីលេខ៣ កុមារី **ខឿន ស្រីនូ** សិស្សរៀន ប.សម្តេចក្រុមព្រះ ខេត្តរតនគិរី
ទទួលបានថវិកាលើកទឹកចិត្ត១.០០០.០០០៛

(ឧ.រូបភាពទី១០)

### ជ័យលាភី ផ្នែកស្មូតកំណាព្យ




ជ័យលាភីលេខ១ កុមារី **វៃ ស្រីពេជ្រ** សិស្សរៀន វិ.ស្តៅសន្តិភាព ខេត្តបាត់ដំបង
ទទួលបានថវិកាលើកទឹកចិត្ត ៤.០០០.០០០៛
ជ័យលាភីលេខ២ កុមារី **រ៉ាត ចន្ទសោភា** សិស្សរៀន វិ.ស្រអែម ខេត្តព្រះវិហារ
ទទួលបានថវិកាលើកទឹកចិត្ត ៣.០០០.០០០៛
ជ័យលាភីលេខ៣ កុមារា **ឌុម បញ្ញា** សិស្សរៀន អនុវិ.អំពិលទោលខេត្តព្រៃវែង
ទទួលបានថវិកាលើកទឹកចិត្ត ២.០០០.០០០៛

(ឧ.រូបភាពទី ១១)

### ជ័យលាភី ផ្នែកតែងនិពន្ធ




ជ័យលាភីលេខ១ កុមារី **គុង មិនា** សិស្សរៀន វិ.ព្រះបាទសុរាម្រឹតខេត្តកំពង់ឆ្នាំង
ទទួលបានថវិកាលើកទឹកចិត្ត ៦.០០០.០០០៛
ជ័យលាភីលេខ២ កុមារី **អាន រក្សា** សិស្សរៀន វិ. ក្រែក ខេត្តត្បូងឃ្មុំ
ទទួលបានថវិកាលើកទឹកចិត្ត ៥.០០០.០០០៛
ជ័យលាភីលេខ៣ កុមារី **អេង ស្រីយ៉ា** សិស្សរៀន វិ. ប៊ូស្រា ខេត្តមណ្ឌលគិរី
ទទួលបានថវិកាលើកទឹកចិត្ត ៤.០០០.០០០៛

(ឧ.រូបភាពទី ១២)

**បញ្ជាក់** ៖ សម្រាប់បេក្ខជនជ័យលាភី អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធខាងលើនេះ ក្រៅពីថវិកាលើកទឹកចិត្ត ត្រូវទទួលបាន " **ពាន សម្តេចតេជោ ហ៊ុនសែន** " និងប្រកាសនីយបត្រតាមប្រភេទជ័យលាភីរបស់ខ្លួន និង Kindle White Paper ១ គ្រឿង ព្រមទាំងសម្ភារៈសិក្សា១កាបូបថែមទៀត។

### ជ័យលាភី ផ្នែកបកស្រាយប្រធានបទអក្សរសិល្ប៍

លេខ១ លោក ជក់ សុភា គ្រូបង្រៀន នៅសាលាជំនាន់ថ្មី វិទ្យាល័យ ព្រែកលៀប រាជធានីភ្នំពេញ
លេខ២ លោក រ៉ឹក សារ៉ន់ គ្រូបង្រៀន នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៃវែង ខេត្តព្រៃវែង
លេខ៣ លោក ទឹម សុខហួយ គ្រូបង្រៀន នៅវិទ្យាល័យអង្គសង្កែ ខេត្តតាកែវ
លេខ៣ លោក ឡុង ធវង្ស គ្រូបង្រៀន នៅវិទ្យាល័យសម្តេច អគ្គ. ហ.ស សំរាង រាជធានីភ្នំពេញ

(ឧ.រូបភាពទី ១៤)

ក្នុងកម្មវិធីប្រឡងប្រណាំងទាំង៤ផ្នែកនេះមាន អង្គការ Aid et Action បានឧបត្ថម្ភថវិកា ៣.០០០ដុល្លា សម្រាប់ក្រុមការងាររៀបចំទិវាជាតិអំណានលើកទី៦ និងសម្រាប់ជ័យលាភីបកស្រាយប្រធានបទអក្សរសិល្ប៍ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ បានឧបត្ថម្ភ Kindle White Paper ០៩គ្រឿង ជូនដល់ជ័យលាភីប្រឡងប្រណាំងទាំង០៣ផ្នែក។ សម្ភារៈទាំងអស់នេះ ក្រសួងនឹងរៀបចំចាត់ចែងប្រគល់ជូនដល់បេក្ខជនទាំងអស់ នៅតាមបណ្តា រាជធានី ខេត្ត នាពេលក្រោយ។

### ឃ.ការអានអត្ថបទនិងសូត្រកំណាព្យ ដោយជ័យលាភីលេខ១



កុមារី **យុន ជីនីតា** សិស្សថ្នាក់ទី៦ ប.អនុវត្ត ខេត្តព្រះវិហារ ជាជ័យលាភីលេខ១ ផ្នែកអានអត្ថបទ បានអានអត្ថបទមានចំណងជើងថា " **រឿង អ្នកគ្រូរបស់គុណ** " ។



កុមារី **ទឹម ស្រីពេជ្រ** សិស្សថ្នាក់ទី៧ វិ.ស្ពានសន្តិភាព ខេត្តបាត់ដំបង ជាជ័យលាភីលេខ១ ផ្នែកសូត្រកំណាព្យ បានសូត្រកំណាព្យ បទពាក្យ ៧ មានចំណងជើងថា " **អំណានក្នុងបរិបទកូវីដ-១៩** " សូត្របែប មេទ្រីបា។

### ង. បាឋកថា ស្រាវជ្រាវ ស្តីពី " អក្សរសិល្ប៍ និងភាសាខ្មែរសម័យកណ្តាល តាមរយៈសិលាចារឹកនគរវត្ត "



ក្រៅពីភារកិច្ចដឹកនាំកំណែទម្រង់ វិស័យអយក. **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានស្រាវជ្រាវចងក្រងបានឯកសារជាច្រើនសម្រាប់សិស្ស និស្សិត និងសាធារណៈជនសិក្សាបន្ថែមទៀត។ បាឋកថាស្រាវជ្រាវ ស្តីពី " **អក្សរសិល្ប៍ និងភាសាខ្មែរសម័យកណ្តាល តាមរយៈសិលាចារឹកនគរវត្ត** " ជាស្នាដៃតែងនិពន្ធសៀវភៅទី៣១ របស់លោក។



ខ្លឹមសារសំខាន់ៗនៃឯកសារដែល **ឯកឧត្តមបណ្ឌិតសភាចារ្យ** លើកយកមកបង្ហាញមាន ៤ ជំពូក និង ៣ ផ្នែក គឺ៖

ជំពូក ទី១ ការវិវត្តភាសាខ្មែរ ពីខ្មែរចាស់ មកខ្មែរកណ្តាល

ជំពូក ទី២ ប្រភពនៃការសិក្សាភាសាខ្មែរកណ្តាល

ជំពូក ទី៣ លក្ខណៈទូទៅនៃភាសាខ្មែរកណ្តាល

ជំពូក ទី៤ អត្ថន័យនៃសិលាចារឹកនគរវត្ត

ផ្នែក ទី៥ វេយ្យាករណ៍ភាសាខ្មែរកណ្តាល

ផ្នែក ទី៦ ការវិវត្តសូរស័ព្ទ

ផ្នែកទី៧ ការវិវត្តិភាសាខ្មែរក្នុងរយៈពេល៣សតវត្ស ពីភាសាខ្មែរកណ្តាល មកភាសាខ្មែរទំនើប។

ជារួមភាសាខ្មែរកណ្តាល បានទទួលឥទ្ធិពលយ៉ាងខ្លាំងក្លាពីទស្សនៈ និងវាក្យស័ព្ទនៃព្រះពុទ្ធសាសនា ថេរវាទ និងភាសាបាលី ថ្វីត្បិតតែភាសាសំស្ក្រឹត និងភាសាខ្មែរចាស់ នៅបន្តចាក់ឫសក្នុងវាក្យស័ព្ទនៃភាសាខ្មែរកណ្តាល។ ប៉ុន្តែ ការសរសេរភាសាបាលីនៅក្នុងសិលាចារឹកនគរវត្ត មិនបានត្រឹមត្រូវទៅតាមក្បួនច្បាប់ទេ ដែលនេះបង្ហាញថា ថ្វីត្បិតតែព្រះពុទ្ធសាសនា បានចាក់ឫសចូលជ្រៅ ក្នុងសង្គមកម្ពុជានៅសម័យលង្វែក តែវត្តអារាមនៅមិនទាន់ក្លាយជាកន្លែងសម្រាប់សិក្សាភាសាបាលីឡើយ។

### ច. ការបកស្រាយប្រធានបទ " តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ "




លោក **ជាក់ សុភា** គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីនៃវិទ្យាល័យព្រែកលាប រាជធានីភ្នំពេញ ជាបេក្ខជន ជ័យលាភីលេខ១ ផ្នែកបកស្រាយប្រធានបទ ស្តីពី "តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ" បានបកស្រាយ ប្រធានបទនេះ មានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម ៖

**១.សារៈតារនៃរឿង**

. រឿងរាមកេរ្តិ៍ជាស្នាដៃដ៏ពិសិដ្ឋមួយ ដែលដក់ជាប់ក្នុងអារម្មណ៍ប្រជាជាតិខ្មែរ ចាប់ពីព្រះមហាក្សត្រ រហូតដល់ប្រជារាស្ត្រ និងតាំងពីសម័យបុរាណ រហូតដល់បច្ចុប្បន្ន ។

. រឿងរាមកេរ្តិ៍មានប្រភពចេញពីរឿងរាមាយាណៈ ដែលជាវីរកថាមួយរបស់ប្រទេសឥណ្ឌា

. កាលបរិច្ឆេទនិពន្ធ ប្រហែលនៅសតវត្សទី១២ និងទី១៣

. មាននៅក្នុងកម្មវិធីសិក្សានៃព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ១៩៥៨ មកដល់បច្ចុប្បន្ន។

**២.ទម្រង់រឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ**




. ក្នុងសិល្បៈចម្លាក់ ក្នុងសិលាចារឹក ក្នុងផ្ទាំងគំនូរ ក្នុងទស្សនីយភាព

. ក្នុងស្នាដៃអក្សរសិល្ប៍រឿងរាមកេរ្តិ៍ ដូចជា ល្បើកអង្គរវត្ត(អ្នកប៉ង)គ.ស.១៦២០, និរាសនគរវត្ត ឧកញ៉ាសុត្តន្តប្រីជាឥន្ទ...។ល។

**៣.តម្លៃអក្សរសិល្ប៍រឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ**

. ព្រាហ្មណ៍សាសនាក្នុងរឿងរាមកេរ្តិ៍

. សភាវៈល្អ ឈ្នះ សភាវអាក្រក់ (ព្រះរាមថ្លែងសរ ... ) និងការបណ្តុះស្មារតីសន្តិភាព

. តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ ៖ អត្ថន័យ ( លក្ខណៈមនុស្សនិយម និងប្រាកដនិយម ), អត្ថរូប ( បទកាព្យចម្រុះមាន បទពំនោល បទព្រហ្មគីតិ......) , អត្ថរស់ ( បច្ចេករស វិសេសរស សព្វរស ... )

. តម្លៃវប្បធម៌ ៖ ទំនៀមទម្លាប់ ( ពិធីច្រត់ព្រះនង្គ័ល , ពិធីអាពាហ៍ពិពាហ៍ ... ) , ជំនឿ ( ការទស្សន៍ទាយ , ការដាក់បណ្ដាសារ... ) , ការដាក់ឈ្មោះ ( នរនាម , ស្ថាននាម , នាមទូក... )

. ភាពជាអ្នកដឹកនាំ ៖ ការគោរពពាក្យសត្យ ( ព្រះរាម.... )

. និម្មិតរូបតួអង្គ ៖ ចម្លាក់តាមសួនច្បារ និងឡូហ្គោ

. ផ្នត់គំនិត ៖ ការលើកតម្កើងស្ត្រី , ការគោរពពាក្យសត្យ , ភក្ដីភាព...

. សិល្បៈ ៖ របាំព្រះរាជទ្រព្យ , ល្ខោនព្រះរាជទ្រព្យ , ល្ខោនខោល , ល្ខោនស្បែកធំ ...

ជារួមរឿងរាមកេរ្តិ៍ បានបង្កប់ និងបង្ហាញនូវលក្ខណៈមនុស្សនិយម ប្រាកដនិយមជាច្រើន ដែលផ្ដល់នូវគំនិត ចំណេះដឹង ទស្សនទានក្នុងការអប់រំសីលធម៌ គុណធម៌មនុស្ស ដែលអាចទុកជាគម្រូសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ក្នុងការតាក់តែងនិពន្ធ ទាំងវិធីសាស្ត្រ និងទាំងការប្រើប្រាស់ពាក្យពេជន៍។

សំណួរ សូមជួយបញ្ជាក់ពីមនោនិយម និងប្រាកដនិយមនៃរឿងរាមកេរ្តិ៍

ចម្លើយ ជាការគោរពពាក្យសម្បថ និងការគោរពពាក្យសច្ចៈរបស់ព្រះមហាក្សត្រ

សំណួរ តើរឿងរាមកេរ្តិ៍បានអប់រំអ្វីខ្លះដល់សិស្សានុសិស្ស?

ចម្លើយ សាច់រឿងបង្ហាញថា ព្រះរាមបានអប់រំ និងជំរុញកូនឱ្យខិតខំរៀនសូត្រ

**ធ.បទបង្ហាញ ស្ដីពី " ស្ថានភាពបណ្ណាល័យនៅសាលាបឋមសិក្សាក្នុងប្រទេសកម្ពុជា "**



កម្មវិធីនេះ ត្រូវបានធ្វើបទបង្ហាញដោយវាគ្មិនកិត្តិយស ឯកឧត្តម បណ្ឌិត **ចាន់ សុផា** អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន និង ជាប្រធាននាយកដ្ឋានបឋមសិក្សា មានខ្លឹមសារដូចខាងក្រោម៖

១. ប្រកាសលេខ ៤១៦ អយក.ប្រក ចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១ ស្ដីពី ការអនុញ្ញាតឱ្យបោះពុម្ពនិងប្រើប្រាស់ឯកសារណែនាំប្រតិបត្តិបណ្ណាល័យបឋមសិក្សា ត្រូវបានចែកចេញជា ៣ ផ្នែក ផ្នែកទី១ ការបង្កើតនិងគ្រប់គ្រងបណ្ណាល័យ ផ្នែកទី២ សកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ និងផ្នែកទី៣ បញ្ជីសៀវភៅរឿងកុមារ។ ឯកសារនេះ បានគាំទ្រ និងជំរុញយ៉ាងខ្លាំងដល់ការរៀបចំបណ្ណាល័យ និងការអានរបស់កុមារកម្រិតបឋមសិក្សា។



២. ការងារបណ្ណាល័យ និងតួនាទី ភារកិច្ចរបស់បណ្ណារក្ស

**ក.សាវតារ**

. ចាប់ពីសតវត្សទី១៩ បណ្ណាល័យកុមារ មានដើមកំណើតដំបូងនៅប្រទេសអាមេរិក និងអង់គ្លេស

. សតវត្សទី២០ បណ្ណាល័យកុមារ ត្រូវបានបង្កើត និងពង្រីកនៅតាមប្រទេសកំពុងអភិវឌ្ឍនានា

. មុនឆ្នាំ១៩៧៥ នៅកម្ពុជា បណ្ណាល័យសាធារណៈ មាននៅតែភ្នំពេញ និងទីរួមខេត្តនានា

. ក្នុងរបប ប៉ុល ពត បណ្ណាល័យសាធារណៈទាំងអស់ ត្រូវបានបំផ្លិចបំផ្លាញ

. ឆ្នាំ១៩៨០ មជ្ឈមណ្ឌលអំណាននានា បានចាប់ដំណើរការឡើងវិញ ប៉ុន្តែនៅជួបការលំបាកជាច្រើន

. ឆ្នាំ១៩៩០ បណ្ណាល័យកុមារចាប់ផ្ដើមបង្កើត ដោយមានការចូលរួមពីដៃគូអភិវឌ្ឍ ដូចជា RTR, SVA,

SIPAR និងដៃគូពាក់ព័ន្ធមួយចំនួនទៀត

. ឆ្នាំ២០០៤ ក្រសួងអប់រំ សហការជាមួយដៃគូអភិវឌ្ឍ រៀបចំឯកសារសម្រាប់បណ្តុះបណ្តាលបណ្ណារក្ស

. ឆ្នាំ២០១១ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតឡើងស្តង់ដាបណ្ណាល័យបឋមសិក្សា

. ថ្មីៗនេះ ដោយមានការចង្អុលបង្ហាញពី **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ក្រុមការងារកំពុងរៀបចំគោលការណ៍ណែនាំប្រតិបត្តិ សម្រាប់ជំរុញការអនុវត្តការងារបណ្ណាល័យ និងអំណានក្នុងបណ្ណាល័យ។

**ខ.គោលបំណងក្នុងការជំរុញការងារបណ្ណាល័យ**

. លើកទឹកចិត្ត បណ្តុះទម្លាប់សិស្សឱ្យស្រឡាញ់ការអាន ដើម្បីផ្លាស់ប្តូរទម្លាប់ក្នុងការសិក្សា

. លើកទឹកចិត្តគ្រូបង្រៀន ឱ្យចេះសហការជាមួយបណ្ណារក្ស និងផ្សារភ្ជាប់ការសិក្សា ទៅនឹងស្រាវជ្រាវ

. លើកទឹកចិត្តសហគមន៍ អាជ្ញាធរដែនដី ឱ្យចូលរួមជាមួយសាលារៀន

. លើកទឹកចិត្តដៃគូពាក់ព័ន្ធឱ្យចូលរួមការលើកម្ពស់គុណភាពអប់រំ តាមរយៈបណ្ណាល័យ

. បង្ហាញពីសារៈសំខាន់នៃការងាររបស់បណ្ណារក្ស ក្នុងការបំពេញការងារនៅក្នុងបណ្ណាល័យ។

**គ.សមិទ្ធិផលសំខាន់ៗសម្រេចបាន**

. បានរៀបចំឯកសារណែនាំប្រតិបត្តិ ស្តីពីការងារបណ្ណាល័យនៅសាលារៀនបឋមសិក្សា

. បានបំប៉នសមត្ថភាពស្តីពីការងារបណ្ណាល័យដល់បណ្ណារក្ស ១៨២៩នាក់ស្រី៩១២នាក់នៅ៨ខេត្ត

. បានចែកជូនសៀវភៅភាសាអង់គ្លេសចំនួន៣៨៨៨០ក្បាលដល់៨ខេត្ត( ឧបត្ថម្ភ អង្គការរូមធូរីដ )

. បានផ្តល់សៀវភៅសម្រាប់អានចំនួន១៨៩៤០ក្បាលដល់បណ្ណាល័យ៤៨ ក្នុងខេត្តទាំង៧

**ឃ. បណ្ណាល័យបឋមសិក្សា**

បង្ហាញពី និយមន័យបណ្ណាល័យ តួនាទីបណ្ណាល័យ ផលប្រយោជន៍បណ្ណាល័យ និងតួនាទីបណ្ណារក្ស។

**ង. ប្រភេទបណ្ណាល័យ**

ប្រភេទបណ្ណាល័យមាន បណ្ណាល័យជាអគារ,បណ្ណាល័យជាបន្ទប់,បណ្ណាល័យក្នុងទីចាត់ការ,បណ្ណាល័យនៅក្នុងថ្នាក់, បណ្ណាល័យចល័ត, បណ្ណាល័យឌីជីថលនិងអ៊ី-បណ្ណាល័យ និងបណ្ណាល័យស្វ័យប្រវត្តិ។

ជារួម សាលារៀនដែលមានបណ្ណាល័យហើយដំណើរការបានល្អ យើងឃើញថាជាទូទៅសិស្សានុសិស្សនៅសាលារៀននោះតែងមានភាពក្លាហាន ចេះគួរសម មានវិន័យ និងមានការសិក្សាបានល្អប្រសើរ ជាងសាលារៀនដែលមិនទាន់មានបណ្ណាល័យ ឬបណ្ណាល័យដំណើរការមិនទាន់បានល្អ។

**ជ.បទបង្ហាញ ស្តីពី " ការងារបណ្ណាល័យ ផ្សារភ្ជាប់នឹងសកម្មភាពអំណានដំបូង "**




កម្មវិធីនេះត្រូវបានធ្វើបទបង្ហាញដោយវាគ្មិនកិត្តិយស លោក **ជា វណ្ណថា** នាយកប្រតិបត្តិអង្គការរូមធូរីដកម្ពុជា មានខ្លឹមសារសំខាន់ជាបន្តបន្ទាប់ដូចខាងក្រោម៖

ក. ការភ្ជាប់រវាងកម្មវិធីអំណានថ្នាក់ទី១-៦ និងកម្មវិធីសមភាពយេនឌ័រ ថ្នាក់ទី៧-១២

. កម្មវិធីអំណាន ថ្នាក់ទី១-៦៖ ដើម្បីពង្រឹងបំណិនអាន និងសរសេរ និងបណ្តុះទម្លាប់នៃការអាន

. កម្មវិធីសមភាពយេនឌ័រ ថ្នាក់ទី៧-១២ ៖ កាត់បន្ថយអត្រាបោះបង់សិស្សស្រី និងមានបំណិនចាំបាច់ដើម្បីជួយឱ្យពួកគេទទួលបានជោគជ័យទាំងនៅក្នុងសាលានិងក្នុងជីវិតរស់នៅរបស់ពួកគេ។

ខ. លទ្ធផលកម្មវិធីអំណាន និងសមភាពយេនឌ័រសំខាន់ៗ

គ. ការបកស្រាយពីឯកសារណែនាំប្រតិបត្តិការងារបណ្ណាល័យ

ផ្នែកទី១ ការបង្កើត និងគ្រប់គ្រងបណ្ណាល័យ ៖ ធ្វើផែនការបង្កើតបណ្ណាល័យ, បង្កើតបណ្ណាល័យ, ដំណើរការ

បណ្ណាល័យ, គ្រប់គ្រងបណ្ណាល័យ, ការធ្វើឱ្យបណ្ណាល័យមាននិរន្តរភាព។

ផ្នែកទី២ សកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ ៖ អំណានឮ, អំណានចូលរួម, អំណានដៃគូ, អំណានបុគ្គល។

ផ្នែកទី៣ បញ្ជីរឿងសៀវភៅសម្រាប់កុមារ ៖ របៀបកំណត់កម្រិតអានតាមសៀវភៅនីមួយៗ, ឈ្មោះក្រុមហ៊ុន ឬសហគ្រាសបោះពុម្ពផ្សាយនៅកម្ពុជា, បញ្ជីសៀវភៅតាមកម្រិត ដែលសាលាអាចរកជាវសម្រាប់បំពាក់នៅតាមបណ្ណាល័យ។

សំណួរ តើក្រសួងអប់រំ យុវជន និងកីឡា មានវិធានការដូចម្ដេចខ្លះ ដើម្បីធានានិរន្តរភាពដំណើរការបណ្ណាល័យ?

ចម្លើយ ពង្រឹងអំណាននៅក្នុងថ្នាក់ ដោយអនុវត្តកម្មវិធីអំណាន ពិសេសពង្រឹងសមត្ថភាពគ្រូនៅក្នុងការដឹកនាំអំណានក្នុងថ្នាក់រៀន។

សំណួរ តើអ្នកពាក់ព័ន្ធមានតួនាទីនិងបច្ចេកទេសបែបណាក្នុងការជំរុញនិងលើកកម្ពស់ការអាននិងឈានទៅបណ្តុះទម្លាប់អានពេញមួយជីវិត?

ចម្លើយ . ពង្រឹងអំណាននៅក្នុងបណ្ណាល័យ ដោយត្រូវធ្វើឱ្យបណ្ណាល័យជាបណ្ណាល័យមេត្រី

. លើកទឹកចិត្ត និងជំរុញការអានសៀវភៅទាំងក្នុងសាលា និងក្រៅសាលា តាមរយៈម៉ោងបណ្ណាល័យក្នុងកាលវិភាគ និងកិច្ចការស្រាវជ្រាវ សម្រាប់សិស្សថ្នាក់មធ្យមសិក្សា ។

### ឈ.ការចាក់បង្ហាញ វីដេអូ ស្តីពី " សកម្មភាពអំណានក្នុងបណ្ណាល័យ "

ខ្លឹមសារវីដេអូត្រូវបានចែកចេញជាពីរវគ្គគឺ ៖

វគ្គទី១ ស្តីពី បទពិសោធន៍នៃការផ្សារភ្ជាប់អំណានថ្នាក់ដំបូងនឹងអំណានក្នុងម៉ោងបណ្ណាល័យ



វគ្គទី២ ស្តីពី សកម្មភាពអំណានចូលរួមក្នុងម៉ោងបណ្ណាល័យ



# ប្រសាសន៍ប្រកសរុប និងបិទកម្មវិធី
# ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា




ប្រសាសន៍របស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មានខ្លឹមសារដូចខាងក្រោម៖

ឯកឧត្តម បណ្ឌិតសភាចារ្យ បានសំដែងអំណរគុណជូនដល់គ្រប់ស្រទាប់មហាជនដែលបានចូលរួម និងតាមដានការប្រារព្ធ និងផ្សាយបន្តផ្ទាល់ទិវាជាតិអំណានលើកទី៦ តាមអនឡាញ ដល់ក្រុមការងារ និងមន្ត្រីបច្ចេកទេសដែលបានរៀបចំ និងថ្នាក់ដឹកនាំនិងមន្ត្រីមន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត ដែលបានរៀបចំការប្រឡងប្រណាំងដោយជ្រើសរើសបានបេក្ខជនជ័យលាភី សម្រាប់មកប្រឡងប្រណាំងជ័យលាភីថ្នាក់ជាតិ និងការចូលរួមការប្រារព្ធទិវាជាតិតាមអនឡាញ និងតាមរាជធានី ខេត្តរៀងៗខ្លួន។.

ឯកឧត្តម បណ្ឌិតសភាចារ្យ បានបញ្ជាក់ថា នៅឆ្នាំ២០១៣កំណែទម្រង់ក្របខណ្ឌវង្វាយតម្លៃថ្នាក់ជាតិត្រូវបានធ្វើឡើង ដូចជា ការវាយតម្លៃអំណានថ្នាក់ដំបូងក្នុងកម្រិតតំបន់ និងការត្រៀមធ្វើតេស្តកម្រិតថ្នាក់អន្តរជាតិនៅពេលខាងមុខនេះ។ លទ្ធផលនៃវង្វាយតម្លៃនេះនឹងជួយលើកកម្ពស់វិធីសាស្ត្របង្រៀន និងគរុកោសល្យជាពិសេស សកម្មភាពគ្រូនៅក្នុងថ្នាក់ ជាមួយនឹងលទ្ធផលរៀនសូត្ររបស់សិស្ស។

ការអនុវត្តអំណានដំបូងគឺ ដើម្បីលើកកម្ពស់បំណិនអំណាន និងកែលម្អវិធីសាស្ត្របង្រៀនរបស់គ្រូ សំដៅលើកកម្ពស់សមត្ថភាពអានរបស់សិស្សអាចអានបានដោយឯករាជ្យ។កុមារត្រូវហ្វឹកហាត់អានសៀវភៅពីជំហានងាយទៅកម្រិតលំបាក។ ក្នុងន័យនេះ ត្រូវរៀបចំឯកសារជំនួយ(ការអាន) ដើម្បីអាចជួយដល់សិស្សបាន រៀនស្គាល់សូរការភ្ជាប់សូរទៅនឹងល្បះ, អាចស្ទាត់ជំនាញ និងអាចយល់បាន។

**វិធានការមួយចំនួន ដើម្បីឱ្យសាលារៀនដែលមានបណ្ណាល័យ មានដំណើរការល្អ**

. បង្កើតបណ្ណាល័យមេត្រីនៅក្នុងសាលា ( ផាសុកភាព , ការរៀបចំហេដ្ឋារចនាសម្ព័ន្ធល្អ ជាដើម)

. បង្កើនទម្លាប់ឱ្យសិស្សចេះស្រឡាញ់សៀវភៅ ( ផ្អែកលើឯកសារណែនាំការងារបណ្ណាល័យ )

. មានម៉ោងបណ្ណាល័យសម្រាប់សិស្ស គឺ១ម៉ោងក្នុង១សប្តាហ៍ សម្រាប់ឱ្យសិស្សចូលបណ្ណាល័យ ។

. មានសកម្មភាពអំណាន លើកទឹកចិត្តសិស្សឱ្យចូលចិត្តចូលបណ្ណាល័យ និងចូលចិត្តអានសៀវភៅ ។

. កម្រិតមធ្យមសិក្សា ត្រូវរៀបចំឆ្លើយតបតាមស្តង់ដាររបស់សិស្សចង់ចេះ ចង់ដឹង ចង់ស្រាវជ្រាវបន្ថែម។

មាតាបិតាត្រូវឧស្សាហ៍នាំកូនទៅបណ្ណាល័យ បណ្ណាគារ ដើម្បីបណ្តុះទម្លាប់កូន ឱ្យស្រឡាញ់សៀវភៅ ។

សមាសភាពនៃអំណានមាន៤ គឺ ១)អំណានលឺ ២)អំណានចូលរួម ៣)អំណានដៃគូរ ៤)អំណានបុគ្គល

សមត្ថភាព និងលទ្ធផលសិក្សារបស់សិស្ស មិនអាចពឹងផ្អែកលើគ្រូទាំងស្រុងទេ គឺពឹងផ្អែកបន្ថែមទៀតលើការគ្រប់គ្រងរបស់នាយក ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការចូលរួមរបស់សហគមន៍ និង មាតាបិតាសិស្ស។

ដូចនេះ គ្រូត្រូវមានសមត្ថភាពវាយតម្លៃសិស្ស គ្រូត្រូវមានបំណិនវិជ្ជាជីវៈ នៅក្នុងកម្រិតវិជ្ជាជីវៈរបស់ខ្លួន។

**វិធានការមួយចំនួន សម្រាប់ការជួយជម្រុញ និងពង្រឹងផ្នែកអំណាន**

១. នា.បឋមសិក្សា ត្រូវរៀបចំសេចក្តីណែនាំថ្នាក់ទី១-ថ្នាក់ទី៣ និងកែលម្អសៀវភៅសិក្សាគោល ដើម្បីលើកកម្ពស់អំណាន

២. នា.អកស ត្រូវរៀបចំសេចក្តីណែនាំថ្នាក់ទី៦ ឱ្យគ្រូបង្រៀនសិស្សសរសេរតាមអានឱ្យបានញឹកញាប់ដូចជា ការសរសេរតាមអាន គ្រូត្រូវសូត្រឱ្យសិស្សសរសេរតាម និងការសរសេរតែងសេចក្តី។

៣. នា.បឋមសិក្សា និងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ត្រូវរៀបចំសេចក្តីណែនាំសម្រាប់ការងារបណ្ណាល័យ ដូចជា បណ្ណាល័យ

មានសៀវភៅគ្រប់គ្រាន់ប្រកបដោយគុណភាព, មានការតម្រូវឱ្យសិស្សចូលអានសៀវភៅ។

៤.នា.ធគអ និងនា.បឋម ត្រូវរៀបចំគម្រូអនុវត្តស្តង់ដារតេស្ត និងពិនិត្យលទ្ធភាពដាក់ចូលក្នុងសៀវភៅសិក្សាគោល

៥.នា.មចទ ត្រូវពង្រីកចំនួនសាលាដែលគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព និងសិស្សត្រូវហាត់រៀនខ្លួនឯង និងស្រាវជ្រាវឱ្យបានច្រើន អានសៀវភៅឱ្យបានច្រើន

៦.នា.អកស ត្រូវរៀបចំឱ្យមានបណ្ណាល័យគម្រូ មានសៀវភៅគ្រប់កម្រិតថ្នាក់ ពិសេសការ អនុវត្តវិធីសាស្ត្របង្រៀនថ្មី ដោយឱ្យសិស្សចេះធ្វើការងារជាក្រុម , បង្រៀនសិស្សឱ្យចេះស្រាវជ្រាវ ពិសេសឱ្យសិស្សមានបំណិនសតវត្សទី២១ , បង្រៀនសិស្សឱ្យចេះឆ្ងល់ សរសេរឱ្យបានច្រើនគ្រប់កម្រិត

៧. នា.មចទ ត្រូវរៀបចំសេចក្តីណែនាំអនុវត្តការសរសេរតាមអាន និងតែងសេចក្តីឱ្យបានញឹកញាប់ ដែលអាចដកស្រង់ចេញពីសៀវភៅសិក្សាគោល និងសៀវភៅផ្សេងៗទៀត។

៨.នា.ធគអ សហការជាមួយនា.មចទ រៀបចំគម្រូតេស្តអន្តរជាតិ

៩.នា.បវ ត្រូវចុះស្រាវជ្រាវដើម្បីដឹងពីចំណុចខ្វះខាត រៀបចំបណ្តុះបណ្តាលគ្រូពីវិធីសាស្ត្របង្រៀន ពិសេសបណ្តុះបណ្តាលគរុកោសល្យ បំប៉នគ្រូ នៅតាមសាលាគរុកោសល្យ ពីវិធីសាស្ត្របង្រៀនថ្មីអំណានដំបូង។

១០.នា.ធគអ, នា.មចទ និងនា.បឋម ត្រូវពិនិត្យមើលថាតើ ត្រូវពិនិត្យមើលប៉ុន្មានដង លើការកម្រិតវាយតម្លៃតេស្ត ត្រូវប្រើប្រាស់គ្រូវាយតម្លៃណា។

ចុងបញ្ចប់ **ឯកឧត្តម បណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** បានអំពាវនាវ

១. គ្រប់គ្រឹះស្ថានសិក្សាទាំងអស់ ត្រូវលើកកម្ពស់ស្តង់ដារអនាម័យសាលារៀន ដោយបង្រៀនសិស្សឱ្យលាងដៃឱ្យបានញឹកញាប់ មិនត្រូវចូលទៅកន្លែងបិតជិត ជៀសវាងកុំទៅកន្លែងដែលមានមនុស្សអ៊ូអរច្រើន

២. អនុវត្តពាការពារ និង៣កុំ តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល

៣. ការបន្ត ការបង្រៀន ប្រកបដោយសុវត្ថិភាព គឺកម្មវិធីបង្រួមឱ្យខ្លី កុំឱ្យថ្នាក់រៀនមានភាពកុះករ។

## IV. សេចក្តីសន្និដ្ឋាន

ទោះបីព្រះរាជាណាចក្រកម្ពុជាយើងកំពុងស្ថិតក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈនៃជំងឺកូវីដ-១៩ ក៏ការរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១ បានប្រព្រឹត្តទៅដោយរលូនតាមអនឡាញ និងតាមកម្មវិធីដែលបានគ្រោងទុក និងអនុវត្តគោរពតាមសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលបានយ៉ាងម៉ឺងម៉ាត់ ដោយមាន មហាជន មន្ត្រីរាជការ សិស្ស និស្សិត បានចូលរួមក្នុងកម្មវិធីដែលបានផ្សាយតាមអនឡាញ និងតាមផេកហ្វេកប៊ុករបស់ក្រសួងអប់រំ ដោយការយកចិត្តទុកដាក់ ព្រមទាំងចូលរួមក្នុងកម្មវិធីសប្តាហ៍សៀវភៅលើទំព័រផេកនិងវីដេអូ ២២៩,៦៧២ គណនី។

ទន្ទឹមនឹងគុណសម្បត្តិខាងលើនេះ ក៏នៅមានចំណុចខ្វះខាតបន្តិចបន្តួច ដែលចំណុចខ្វះខាតនេះនឹងក្លាយជាបទពិសោធន៍សម្រាប់បន្តរៀបចំទិវាជាតិអំណានលើកទី៧ ឆ្នាំ២០២២ និងឆ្នាំបន្តបន្ទាប់ទៀត។

ថ្ងៃ ពុធ ៣ រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២១

**អ្នករៀបចំរបាយការណ៍**

**សាម សារុំ**

បានឃើញ និង ឯកភាព

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

## V. ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ផ្នែកព័ត៌មាន និងគណៈកម្មការផ្សេងៗ សម្រាប់ ទិវាជាតិអំណានលើកទី៦ ១១ មីនា ២០២១

រូបភាពទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០៤ អយក.សរាណ

### សេចក្ដីជូនដំណឹង

ការប្រារព្ធទិវាជាតិអំណានលើកទី៦ ឆ្នាំ២០២១ នឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ១៣រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដើម្បីញ៉ាំងឱ្យទិវានេះប្រព្រឹត្តទៅប្រកបដោយភាពអធិកអធម ក្រសួងអប់រំ យុវជន និងកីឡា មានការជ្រើសរើសបេក្ខជន បេក្ខនារី ជ័យលាភី៣រូប ដែលមានសមត្ថភាពខ្ពស់ក្នុងការបកស្រាយប្រធានបទស្ដីពី "**តម្លៃអក្សរសិល្បិ៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ**" ។ សូមសាធារណជន លោកគ្រូ អ្នកគ្រូ គរុសិស្ស និងគរុនិស្សិតចូលរួមក្នុងការប្រឡងប្រណាំងនេះ ដោយអនុវត្តគោលការណ៍ដូចខាងក្រោម៖

**១. ខ្លឹមសារ**

- ប្រធានបទ ៖ "**តម្លៃអក្សរសិល្បិ៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ**"

**២. លក្ខខណ្ឌជ្រើសរើស**

- បកស្រាយប្រធានបទបានល្អ ចាប់ពី៨ ទៅ១០ទំព័រ ក្រដាសA4( សំណេរដោយកុំព្យូទ័រ )
- មានសំនួនវោហារ ឥរិយាបថសមរម្យ ឈ្លាសវៃក្នុងការបកស្រាយបានសមស្រប។

**៣. ការវាយតម្លៃ**

ស្នាដៃទាំងអស់ត្រូវឆ្លងកាត់ការវាយតម្លៃជ្រើសរើសមានបីដំណាក់កាល៖

- **ដំណាក់កាលទី១៖** គណៈកម្មការបច្ចេកទេស ពិនិត្យជ្រើសរើសស្នាដៃ និងមានខ្លឹមសារល្អលើសគេ ចំនួន១០ រូប ដើម្បីដាក់ជូនគណៈកម្មការអនុម័ត។
- **ដំណាក់កាលទី២៖** គណៈកម្មការអនុម័ត របស់ក្រសួងអប់រំ យុវជន និងកីឡា នឹងជ្រើសរើសស្នាដៃ បេក្ខជន ចំនួន៥ រូប ដើម្បីធ្វើសម្ភាសនៅដំណាក់កាលចុងក្រោយ។
- **ដំណាក់កាលទី៣៖** ការសម្ភាសផ្នែកសំនួនវោហារការបកស្រាយប្រធានបទ ជ្រើសរើសស្នាដៃល្អចំនួន ៣រូប ដឹកនាំដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**៤. ពេលវេលា និងទីកន្លែងទទួល**

- **កាលបរិច្ឆេទទទួលស្នាដៃ៖** ផុតកំណត់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង១៧:០០ នាទី។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

- **កន្លែងទទួល៖** នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ស្ថិតនៅក្នុងបរិវេណអគារថ្មីរដ្ឋបាលថ្មី របស់ក្រសួងអប់រំ យុវជន និងកីឡា ជាប់សាលាបឋមសិក្សាចៅពញាហុក ផ្លូវលេខ៣៨០ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ (ខាងកើតផ្សារបឹងកេងកងចម្ងាយប្រមាណ២០០ម៉ែត្រ)។
- បេក្ខជន-បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមរៀបចំជាស្នាដៃរួចផ្ញើមកតាមរយៈសារអេឡិចត្រូនិច (**តេឡេក្រាម៖ ០១០ ២២០ ៧៨៨/ លេខទូរស័ព្ទ ០១១ ២២៨ ៨៥២**)

ថ្ងៃពុធ ៨កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

អ៊ុំ ក្ញុច

**ចម្លងជូន៖**

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានអប់រំ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ
- គ្រប់គ្រឹះស្ថានសិក្សា
- កាលប្បវត្តិ
- ឯកសារ នា.អកស

រូបភាពទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២៦២ អយក.អកស

ថ្ងៃ ៣ ៦ ៧ កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ ២០២១

**ជម្រាបមក**
**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

កម្មវត្ថុ ៖ ការអនុវត្តសេចក្តីណែនាំលេខ៤៧អយក.សណន ស្តីពី ការប្រារព្ធទិវាជាតិអំណាន ១១ មីនា ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧។

យោង ៖ អនុក្រឹត្យលេខ១២០អនក្រ.បកស្តីពី ទិវាជាតិអំណានចុះថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ២០១៥។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក លោកស្រីប្រធានជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំកម្មវិធីប្រឡងប្រណាំង អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ជ្រើសរើសជ័យលាភីថ្នាក់ជាតិចំណាត់ថ្នាក់លេខ១ ដល់លេខ៣ ទទួលពានរង្វាន់ សម្តេចតេជោ **ហ៊ុន សែន** ដើម្បីអបអរសាទរទិវាជាតិអំណាន ១១ មីនា ២០២១ ក្រោមប្រធានបទ "**អំណានក្នុងបរិបទកូវីដ-១៩**"។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រីប្រធាន រៀបចំដំណើរការប្រឡងប្រណាំងជ័យលាភីថ្នាក់ក្រោមជាតិលេខ១ទាំងបីវិញ្ញាសា និងបញ្ជូនមកនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាឱ្យបានមុនថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ជាកំណត់ (មានគំរូជូនភ្ជាប់)។

១.វិញ្ញាសាប្រឡងប្រណាំង
- ការតែងនិពន្ធ (អត្ថបទពាក្យកាព្យ ឬពាក្យរាយ) សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ
- ការស្មូតកំណាព្យ សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ
- ការអានអត្ថបទ សម្រាប់សិស្សបឋមសិក្សា

២.កាលបរិច្ឆេទ និងទីកន្លែងប្រឡងប្រណាំង
- កាលបរិច្ឆេទប្រឡងប្រណាំងជ័យលាភីថ្នាក់ជាតិ៖ ថ្ងៃទី០៩ ដល់ទី១០ ខែមីនា ឆ្នាំ២០២១
- ទីកន្លែង៖ នៅអគាររដ្ឋបាលថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា (ជាប់សាលាបឋមសិក្សាចៅពញាហុក)។
- ទំនាក់ទំនង៖ (អ៊ីម៉ែល៖ hun.lao@moeys.gov.kh/តេឡេក្រាម៖ ០១២ ៩២៨ ៦៩១)

សូម លោក លោកស្រីប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**រដ្ឋលេខាធិការ**

អ៊ឹម ក្មួច

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានអប់រំ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នា. អកស

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

រូបភាពទី៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ១៥ **អយក.** សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណាន

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីទិវាជាតិអំណាន
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណានដែលមានសមាសភាព ដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. ឯ.ឧ.បណ្ឌិតសភាចារ្យ | **ហង់ជួន** | **ណារ៉ុន** | រដ្ឋមន្ត្រី | ប្រធាន |
| ២. ឯកឧត្តម | **ពិត** | **ចំណាន** | រដ្ឋលេខាធិការប្រចាំការ | អនុប្រធាន |
